**រាជរដ្ឋាភិបាលកម្ពុជា**

**អនុក្រឹត្យ/៤៣ អនក្រ/១០ សីហា ១៩៩៤/ស្តីពីសណ្តាប់ធ្នាប់សាធារណៈនៅរាជធានី ភ្នំពេញ និងខេត្ត ក្រុង**

**រាជរដ្ឋាភិបាលកម្ពុជា**

បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

បានឃើញ ព្រះរាជក្រឹត្យ របស់ព្រះករុណា ព្រះបាទសម្តេច នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

យោងតាមសំណើរបស់រដ្ឋមន្រ្តីក្រសួងមហាផ្ទៃ

**សំរេច**

មាត្រា១:

ការរៀបចំសណ្តាប់ធ្នាប់សាធារណៈ សន្តិសុខសាធារណៈ ភាពស្ងប់ស្ងាត់ អនាម័យ និង ភាពនាំអោយមានសុខភាពល្អ នៅរាជធានីភ្នំពេញ និង ខេត្ត ក្រុងជាកាតព្វកិច្ចរបស់ជនគ្រប់រូបដែល រស់នៅក្នុង ព្រះរាជាណាចក្រកម្ពុជា ។

ជនគ្រប់រូបត្រូវតែគោរពអោយបានហ្មត់ចត់តាមបទបញ្ជានានា របស់អាជ្ញាធររាជធានីភ្នំពេញ និង ខេត្ត ក្រុង ដើម្បីថែរក្សាសណ្តាប់ធ្នាប់សាធារណៈ សន្តិសុខសាធារណៈ ភាពស្ងប់ស្ងាត់ អនាម័យ និង ភាពនាំអោយមានសុខភាពល្អ ទូទាំងព្រះរាជាណាចក្រកម្ពុជា។

មាត្រា២:

ការប្រព្រឹត្តិល្មើសនឹងបទបញ្ជានៃសណ្តាប់ធ្នាប់សាធារណៈ សន្តិសុខសាធារណៈ ភាពស្ងប់ ស្ងាត់ អនាម័យ និង ភាពនាំអោយមានសុខភាពល្អ ដែលមានចែងក្នុងអនុក្រឹត្យនេះ គឺជាបទលហុ។

បទលហុជាបទល្មើសនឹងបទបញ្ជារបស់អាជ្ញាធរមានសមត្ថកិច្ច ក្នុងការរៀបចំការរស់នៅ ជាទូទៅ នៅក្នុងសង្គម នៃព្រះរាជាណាចក្រកម្ពុជា ហើយអាជ្ញាធរមានសមត្ថកិច្ចមានសិទ្ធិដាក់ទណ្ឌកម្មដូចតទៅ :

- ការព្រមាន
- ការពិន័យជាប្រាក់
- ការសំរុះសំរួលពីសំណងនៃការខូចខាត។

មាត្រា៣:

នីតិវិធីនៃការព្រមាន ការពិន័យជាប្រាក់ពី ២.០០០៛ ដល់៥០.០០០៛ និង ការសំរុះសំរួល ពីសំណងនៃការខូចខាតចំពោះបទល្មើសនឹង មាត្រា ៤ មាត្រា ៥ មាត្រា ៦ មាត្រា ៧ មាត្រា ៨ មាត្រា ៩ មាត្រា ១០ មាត្រា ១១ មាត្រា ១២ មាត្រា ១៣ មាត្រា ១៤ មាត្រា ១៥ និង មាត្រា ១៦ នៃ អនុក្រឹត្យនេះ ត្រូវកំណត់ដោយដីកា របស់អាជ្ញាធររាជធានីភ្នំពេញ និង ខេត្ត ក្រុង ដោយមានការយល់ព្រម ពីសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

ប្រាក់ពិន័យនេះ ត្រូវបង់ចូលថវិកាជាតិក្រោយពីកាត់ ៤០ ភាគរយ សំរាប់ផ្តល់ ជារង្វាន់ដល់ភ្នាក់ងារ ឬ អង្គភាពនគរបាលមានសមត្ថកិច្ច។

មាត្រា៤:

ជនណាចោល ឬ ចាក់សំរាមក្រៅពីកន្លែងចាក់សំរាម ឬ ធុងសំរាមដែលកំណត់ដោយ អាជ្ញាធរ មានសមត្ថកិច្ចត្រូវពិន័យជាប្រាក់ ២.០០០៛។ ក្នុងករណីមិនរាងចាលត្រូវពិន័យទ្វេមួយជាពីរ ឬ ជាបី ឬជាបួន តាមការល្មើសជាក់ស្តែង។

មាត្រា៥:

ជនណាចោលខ្មោចសត្វតាមផ្លូវ ឬ ទីធ្លាសាធារណៈ ត្រូវពិន័យជាប្រាក់ ៥. ០០០៛។ ក្នុង ករណីមិនរាងចាលត្រូវពិន័យជាប្រាក់ ១០. ០០០៛។

មាត្រា ៦:

ជនណាចាក់សំរាម កាកសំណល់សាងសង សាកសពសត្វក្នុងអណ្តូង លូក្នុងប្រឡាយបង្ហូរ ទឹកត្រូវពិន័យជាប្រាក់ ១០.០០០៛ ។ ក្នុងករណីមិនរាងចាលត្រូវពិន័យជាប្រាក់ ២០.០០០៛ ។

មាត្រា៧:

ជនណារៀបចំពិធីបុណ្យផ្សេងៗ នៅលើទីសាធារណៈ ហើយមិនបោសសំអាតអោយស្អាត ដូចដើម ត្រូវពិន័យជាប្រាក់ ៥០.០០០៛ ។

មាត្រា៨:

គ្រប់អាគារ សណ្ឋាគារ ភូមិគ្រឹះ ស្ថាប័ន ក្រសួងទាំងអស់ត្រូវមានធុងសំរាម ។ ក្នុងករណីគ្មានធុងសំរាម ហើយបោសសំរាមគរ ស្អុយប៉ះពាល់ដល់សុខភាពអ្នកជិតខាង ត្រូវហៅ មកព្រមាន ជាបឋម ។ ក្នុងករណីពុំរាងចាលត្រូវពិន័យជាប្រាក់ ២០.០០០៛ ។

មាត្រា៩:

ជនណាសងសង់បង្គន់ខ្វះអនាម័យ បណ្តាលអោយធុំក្លិនស្អុយប៉ះពាល់ដល់សុខភាពអ្នកជិតខាងត្រូវហៅមកព្រមានជាបឋម។ ក្នុងករណីពុំរាងចាលត្រូវពិន័យជាប្រាក់ ២០.០០០៛។

មាត្រា១០:

ជនណាហាលខោអាវនៅពីមុខផ្ទះនាំអោយខូចសោភ័ណ្ឌភាពរាជធានីភ្នំពេញ ខេត្ត ក្រុងត្រូវព្រមានជាបឋម ។ក្នុងករណីពុំរាងចាល ត្រូវពិន័យជាប្រាក់ ១០.០០០៛ ។

មាត្រា១១:

ជនណាលែងសត្វចតុបាទ អោយដើរពាសវាលពាសកាល ក្នុងទីប្រជុំជននានា នៅលើទីសាធារណៈ ត្រូវចាប់សត្វទាំងនោះ ហៅម្ចាស់មកព្រមានជាបឋម ។ ក្នុងករណីពុំរាងចាល ត្រូវពិន័យជាប្រាក់ ៣.០០០៛ ក្នុងសត្វចតុបាទមួយក្បាល ។

មាត្រា១២:

ជនណាដាក់តាំងទំនិញលក់ គ្មានសណ្តាប់ធ្នាប់នៅលើទីសាធារណៈ ដែលត្រូវហាមឃាត់ ត្រូវហៅមកព្រមានជាបឋម ។ ក្នុងករណីពុំរាងចាលត្រូវពិន័យជាប្រាក់ ១០.០០០៛ ។

មាត្រា១៣:

ជនណារែក ទូល រុញទំនិញ លក់ក្នុងទីសាធារណៈដែលត្រូវហាមឃាត់ត្រូវហៅមកធ្វើការព្រមានជាបឋម ។ ក្នុងករណីពុំរាងចាល ត្រូវពិន័យជាប្រាក់ ២.០០០៛ ។

មាត្រា១៤:

ជនណាសាងសង់សំណង់គ្មានការអនុញ្ញាតត្រឹមត្រូវតាមច្បាប់ ត្រូវហៅមកព្រមាន ចុះកិច្ចសន្យារុះរើដោយខ្លួនឯងជាបឋម ។ ក្នុងករណីពុំរាងចាលត្រូវពិន័យជាប្រាក់ ៥០.០០០៛ និង បង្ខំអោយ រុះរើតាមកិច្ចសន្យា ។

មាត្រា១៥:

ជនណាជីកផ្លូវថ្នល់សាធារណៈ គ្មានការអនុញ្ញាតច្បាប់ត្រឹមត្រូវ ត្រូវពិន័យជាប្រាក់ ៥០.០០០៛ និង សងសោហ៊ុយជួសជុលការខូចខាតដែលខ្លួនបានធ្វើ ។

មាត្រា១៦:

ជនណាបង្កសម្លេងកងរំពង ឬ ឈ្លោះប្រជែកគ្នាធ្វើអោយប៉ះពាល់ដល់ភាពស្ងប់ស្ងាត់ និង សណ្តាប់ធ្នាប់សាធារណៈដោយគ្មាន ការអនុញ្ញាត ត្រូវពិន័យជាប្រាក់ ៥. ០០០៛ ។ ក្នុងករណីពុំរាងចាល ត្រូវពិន័យជាប្រាក់ទ្វេមួយជាពីរ ។

មាត្រា១៧:

បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា១៨:

សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី ក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងអភិបាលគ្រប់ខេត្ត ក្រុងត្រូវ អនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ១៩៩៤

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| នរោត្តម រណឫទ្ធិ | ហ៊ុន សែន |